ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ...៤១០៨...អពដ

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែមិនា ឆ្នាំ ២០១៦

# សេចក្តីណែនាំ
## ស្តីពី
## នីតិវិធីនៃការផ្ទេរការគ្រប់គ្រងសហគ្រាស ពីអង្គភាពពន្ធដារមួយទៅអង្គភាពពន្ធដារមួយទៀតនៃអគ្គនាយកដ្ឋានពន្ធដារ

អនុលោមតាមមាត្រា ១០១ នៃច្បាប់ស្តីពីសារពើពន្ធ ប្រកាសលេខ១០៥៩ សហវ.ប្រក.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីពន្ធលើប្រាក់ចំណេញ និងប្រកាសលេខ១៨១៩ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការធ្វើចំណាត់ថ្នាក់អ្នកជាប់ពន្ធ តាមរបបស្វ័យប្រកាស ដើម្បីពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការគ្រប់គ្រងប្រមូលពន្ធ អគ្គនាយកដ្ឋានពន្ធដារសូមធ្វើការណែនាំអំពីនីតិវិធីនៃការផ្ទេរសហគ្រាសចេញពីការគ្រប់គ្រងសាខាពន្ធដារមួយ ទៅសាខាពន្ធដារមួយទៀត ឬពីសាខាពន្ធដារទៅនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ឬពីនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំទៅសាខាពន្ធដារ ដូចខាងក្រោម÷

### ១. ការស្នើសុំផ្ទេររបស់សហគ្រាស ពីសាខាពន្ធដារមួយទៅសាខាពន្ធដារមួយទៀត

#### ក. នីតិវិធីនៃការស្នើសុំផ្ទេរ

សហគ្រាសត្រូវបំពេញពាក្យស្នើសុំផ្ទេរ (ទម្រង់ C001) រួចដាក់នៅសាខាពន្ធដារដែលកំពុងគ្រប់គ្រងសហគ្រាសដោយភ្ជាប់ឯកសារដូចខាងក្រោម÷

- ប័ណ្ណពន្ធប៉ាតង់ឆ្នាំចុងក្រោយ
- ប័ណ្ណកម្មសិទ្ធិឬកិច្ចសន្យាជួលទីចាត់ការសហគ្រាសចុងក្រោយ
- លិខិតអនុញ្ញាត ឬលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងករណីជានីតិបុគ្គល

#### ខ. នីតិវិធីនៃការផ្ទេរ

ប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ ដែលកំពុងគ្រប់គ្រងសហគ្រាសស្នើសុំផ្ទេរចេញត្រូវអនុវត្តដូចខាងក្រោម÷

- រៀបចំកំណត់បង្ហាញពីសាខាពន្ធដារ ដោយភ្ជាប់សលាកបត្រព័ត៌មាន សលាកបត្រអនុរក្ស០២ឆ្នាំចុងក្រោយ តារាងស្ថានភាពបំណុលសារពើពន្ធ និងឯកសារពាក់ព័ន្ធដូចមានចែងក្នុងចំណុច ១.ក ដើម្បីស្នើសុំការសម្រេចពីអគ្គនាយកដ្ឋានពន្ធដារក្នុងរយៈពេលយ៉ាងយូរបំផុត ០៧ថ្ងៃ នៃថ្ងៃធ្វើការក្រោយថ្ងៃដាក់ពាក្យស្នើសុំ
- ក្នុងករណីសហគ្រាសត្រូវបាននិងកំពុងធ្វើសវនកម្ម សាខាពន្ធដារខេត្ត-ខណ្ឌដែលសហគ្រាសនោះកំពុងស្ថិតនៅ ត្រូវខិតខំបន្តធ្វើសវនកម្មឱ្យបានចប់សព្វគ្រប់ក្នុងរយៈពេល០១ខែគិតចាប់ពីថ្ងៃស្នើសុំ មុននឹងអនុញ្ញាតឱ្យសហគ្រាសផ្ទេរចេញ

Collection by VCAT Professional Consultant

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង ម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

- ក្រោយពីទទួលបានការសម្រេចពីអគ្គនាយកដ្ឋានពន្ធដារ ប្រធានសាខាពន្ធដារខេត្ត-ខណ្ឌត្រូវផ្ទេរសំណុំឯកសារដែលពាក់ព័ន្ធនឹងសហគ្រាសផ្ទេរចេញ មកអគ្គនាយកដ្ឋានពន្ធដារ ដើម្បីអគ្គនាយកដ្ឋានពន្ធដារកត់ត្រាក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ស្តែនទុកហើយ ទើបផ្ទេរទៅឱ្យអង្គភាពថ្មីដែលត្រូវគ្រប់គ្រងសហគ្រាសនោះ ព្រមទាំងផ្ទេរទាំងតួលេខបំណុលពន្ធដែលនៅជំពាក់ ដើម្បីឱ្យអង្គភាពថ្មីនោះគ្រប់គ្រងនិងប្រមូលបំណុលពន្ធដែលសហគ្រាសនៅជំពាក់។

**២. ការផ្ទេរសហគ្រាសពីសាខាពន្ធដារមកនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ឬ ការផ្ទេរពីនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំទៅសាខាពន្ធដារ ដោយរដ្ឋបាលសារពើពន្ធ**

**ក. លក្ខខណ្ឌនៃការផ្ទេរ**

- សហគ្រាសត្រូវបានតម្រូវឱ្យផ្ទេរមកស្ថិតនៅក្រោមការគ្រប់គ្រងនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ក្នុងករណីដែលសហគ្រាសមានផលរបរប្រចាំឆ្នាំលើសពី ២ ០០០ លានរៀល ឬជាសាខាក្រុមហ៊ុនបរទេស ឬជាសហគ្រាសដែលបានចុះបញ្ជីជាគម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ (QIP) ឬទៅតាមការចាំបាច់ដែលមានការសម្រេចពីអគ្គនាយកដ្ឋានពន្ធដារ
- សហគ្រាសត្រូវបានតម្រូវឱ្យផ្ទេរពីនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ឱ្យទៅស្ថិតក្រោមការគ្រប់គ្រងរបស់សាខាពន្ធដារខេត្ត-ខណ្ឌ ក្នុងករណីដែលសហគ្រាសមានផលរបរប្រចាំឆ្នាំ ២ ០០០ លានរៀល ឬតិចជាង។

**ខ. នីតិវិធីនៃការផ្ទេរ**

ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ឬសាខាពន្ធដារខេត្ត-ខណ្ឌដែលគ្រប់គ្រងសហគ្រាសត្រូវអនុវត្តដូចខាងក្រោម៖

- រៀបចំកំណត់បង្ហាញដោយភ្ជាប់សលាកបត្រព័ត៌មាន សលាកបត្រអនុរក្សពីរ(០២)ឆ្នាំចុងក្រោយ តារាងស្ថានភាពបំណុលសារពើពន្ធ និងឯកសារពាក់ព័ន្ធខាងលើ ដើម្បីស្នើសុំការសម្រេចពីអគ្គនាយកដ្ឋានពន្ធដារក្នុងរយៈពេលយ៉ាងយូរបំផុត ០៧ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពេលសហគ្រាសទាំងនោះមានលក្ខខណ្ឌដូចមានចែងក្នុងចំណុច ២-ក
- ក្នុងករណីសហគ្រាសត្រូវបាននឹងកំពុងធ្វើសវនកម្ម នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ឬ សាខាពន្ធដារខេត្ត-ខណ្ឌ ដែលសហគ្រាសនោះកំពុងស្ថិតនៅត្រូវខិតខំបន្តធ្វើសវនកម្មឱ្យបានចប់សព្វគ្រប់ក្នុងរយៈពេល០១ខែគិតចាប់ពីថ្ងៃស្នើសុំ មុននឹងអនុញ្ញាតឱ្យសហគ្រាសផ្ទេរចេញ
- ក្នុងករណីចាំបាច់ដែលមានការសម្រេចពីអគ្គនាយកដ្ឋានពន្ធដារ សហគ្រាសត្រូវបានផ្ទេរដោយមិនចាំបាច់បញ្ចប់សវនកម្ម
- ក្រោយទទួលបានការសម្រេចពីអគ្គនាយកដ្ឋានពន្ធដារ ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ឬប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ ត្រូវផ្ទេរសំណុំឯកសារដែលពាក់ព័ន្ធនឹងសហគ្រាសផ្ទេរចេញ មកអគ្គនាយកដ្ឋានពន្ធដារ ដើម្បីអគ្គនាយកដ្ឋានពន្ធដារកត់ត្រាក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ស្តែនទុកហើយ ទើបផ្ទេរទៅឱ្យអង្គភាពថ្មី ដែលត្រូវគ្រប់គ្រងសហគ្រាសនោះ ព្រមទាំងផ្ទេរទាំងតួលេខបំណុលពន្ធដែលនៅជំពាក់ ដើម្បីឱ្យអង្គភាពថ្មីនោះគ្រប់គ្រងនិងប្រមូលបំណុលពន្ធដែលសហគ្រាសនៅជំពាក់។

Collection by VCAT Professional Consultant

## ៣. នីតិវិធីបន្ទាប់

នាយកដ្ឋានសេវាអ្នកជាប់ពន្ធនិងបំណុលពន្ធ (អនុក្រុមការងារចុះបញ្ជីពន្ធដារ និងធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស) ត្រូវសហការជាមួយនាយកដ្ឋានព័ត៌មានវិទ្យា (ក្រុមការងារព័ត៌មានវិទ្យា) ដើម្បីធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសដែលត្រូវបានផ្ទេរតាមរយៈប្រព័ន្ធគ្រប់គ្រងទិន្នន័យ (ICT) របស់អគ្គនាយកដ្ឋានពន្ធដារក្រោយពីទទួលបានការសម្រេចរបស់អគ្គនាយកដ្ឋានពន្ធដារ ដោយត្រូវអនុវត្តដូចខាងក្រោម÷

- ធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសស្នើសុំផ្ទេរ ឬសហគ្រាសដែលតម្រូវឱ្យផ្ទេរ ដែលមានក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ បន្ទាប់ពីមាន ការសម្រេចរបស់អគ្គនាយកដ្ឋានពន្ធដារ
- បោះពុម្ពប័ណ្ណពន្ធប៉ាតង់ វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ លិខិតជូនដំណឹងទៅអង្គភាពពន្ធដារដែលពាក់ព័ន្ធ និងសហគ្រាស ជាថ្មីឡើងវិញជូនសហគ្រាសស្នើសុំផ្ទេរ
- ស្កេនរាល់សំណុំឯកសារពាក់ព័ន្ធនឹងការស្នើសុំផ្ទេរទាំងអស់ ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ រួចថតចម្លងសំណុំឯកសារនេះមួយច្បាប់ ដើម្បីយកទៅរក្សាទុកនៅមជ្ឈមណ្ឌលរក្សាទុកឯកសាររបស់អគ្គនាយកដ្ឋានពន្ធដារ ជាមួយនឹងសំណុំឯកសារដើមដែលបានស្នើសុំចុះបញ្ជីពន្ធដារកន្លងមក
- ចុះប្រគល់ប័ណ្ណពន្ធប៉ាតង់ វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ លិខិតជូនដំណឹងទៅសហគ្រាស ដល់ទីតាំងផ្ទាល់របស់សហគ្រាស (ករណីប្តូរអាសយដ្ឋាន) ដោយថតរូបទីតាំង និងកត់ត្រាទិន្នន័យរបស់ទីតាំងរបស់សហគ្រាស (GPS) ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដារ ដោយមានម្ចាស់សហគ្រាស ឬអ្នកតំណាងចុះហត្ថលេខាទទួលរាល់សំណុំឯកសារដែលបានប្រគល់។

ទទួលបានសេចក្តីណែនាំនេះ អគ្គនាយករង ប្រធាននាយកដ្ឋាន ប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ និងមន្ត្រីពាក់ព័ន្ធទាំងអស់នៃអគ្គនាយកដ្ឋានពន្ធដារត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

Collection by VCAT Professional Consultant

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

**ទម្រង់ / FORM C 001**

# ពាក្យស្នើសុំផ្ទេរការគ្រប់គ្រងសហគ្រាស ពីអង្គភាពពន្ធដារមួយ ទៅអង្គភាពពន្ធដារមួយទៀត

**APPLICATION FORM FOR TRANSFERRING ENTERPRISE FROM ONE TAX UNIT TO ANOTHER TAX UNIT**

## I. ព័ត៌មានសហគ្រាស / Enterprise information

### ព័ត៌មានសហគ្រាសបច្ចុប្បន្ន / Current information

លេខអត្តសញ្ញាណកម្មសារពើពន្ធ / Tax Identification Number (TIN)

☐☐☐☐-☐☐☐☐☐☐☐☐☐

លេខសម្គាល់
Barcode

ស្ថិតក្រោមការគ្រប់គ្រង
Under

ឈ្មោះសហគ្រាស / Name of enterprise

ឈ្មោះសហគ្រាសជាអក្សរឡាតាំង / Name of enterprise in Latin

- អាសយដ្ឋាន និងលេខទំនាក់ទំនង
  Address and contact number ........................................
- ទម្រង់ទ្រាយសហគ្រាស
  Forms of business ........................................
- កម្រិតផលរបរប្រចាំឆ្នាំ
  Annual turnover ........................................
- ផ្សេងៗ
  Others ........................................

### ព័ត៌មានសហគ្រាសត្រូវផ្ទេរទៅ / Enterprise information to be transfer

លេខអត្តសញ្ញាណកម្មសារពើពន្ធ / Tax Identification Number (TIN)

☐☐☐☐-☐☐☐☐☐☐☐☐☐

លេខសម្គាល់
Barcode

ស្ថិតក្រោមការគ្រប់គ្រង
Under

ឈ្មោះសហគ្រាស / Name of enterprise

ឈ្មោះសហគ្រាសជាអក្សរឡាតាំង / Name of enterprise in Latin

- អាសយដ្ឋាន និងលេខទំនាក់ទំនង
  Address and contact number ........................................
- ទម្រង់ទ្រាយសហគ្រាស
  Forms of business ........................................
- កម្រិតផលរបរប្រចាំឆ្នាំ
  Annual turnover ........................................
- ផ្សេងៗ
  Others ........................................

## II. សេចក្តីប្រកាស / Declaration

ខ្ញុំបាទ/នាងខ្ញុំ សូមធានាអះអាងថា ព័ត៌មានដែលបានប្រកាសខាងលើ ពិតជាត្រឹមត្រូវប្រាកដ ដោយគ្មានប្រតិបត្តិការណាមួយ មិនបានប្រកាសនោះទេ។ យើងខ្ញុំសូមទទួលខុសត្រូវ ចំពោះមុខច្បាប់ ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ។

I hereby assure that all information provided in this form including all attachments is true and accurate and there is no operation undeclared. I shall be punished by the law of the Kingdom of Cambodia if the provided documents are found to be fraudulent or in formation to be incorrect.

កាលបរិច្ឆេទ
Date D D | M M | Y Y Y Y

ហត្ថលេខា ឬស្នាមមេដៃ
Signature or thumb print

ឈ្មោះ
Name

តួនាទី
Position

លេខទូរស័ព្ទ
Telephone Nº



Collection by VCAT Professional Consultant

## សម្រាប់មន្ត្រីពន្ធដារ / TAX OFFICIAL USE ONLY

**មតិអនុប្រធាននាយកដ្ឋាន/អនុប្រធានសាខា**
Comments of Deputy director / Deputy director of tax branch

ហត្ថលេខា
Signature

ឈ្មោះ
Name

លេខសម្គាល់
ID number

កាលបរិច្ឆេទ
Date: ថ្ងៃ / ខែ / ឆ្នាំ

**មតិមន្ត្រីទទួលបន្ទុក**
Comments of Tax official in charge

ហត្ថលេខា
Signature

ឈ្មោះ
Name

លេខសម្គាល់
ID number

កាលបរិច្ឆេទ
Date: ថ្ងៃ / ខែ / ឆ្នាំ

**មតិប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ / ប្រធានសាខាពន្ធដារ**
Commets of Director of department large taxpayer / Director of tax branch

Collection by VCAT Professional Consultant